**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១០៣៣ សហវ.ប្រក.

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០០៥

# ប្រកាស
## ស្តីពី
## ការបង្កើត និងតែងតាំងសមាសភាពគណៈកម្មការជ្រើសរើសភ្នាក់ងារគយនិងរដ្ឋាករ

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ /១១៧ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ /១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ លើលិខិតលេខ ២១៨ សហវ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីសំណើសុំជ្រើសរើសមន្ត្រី និងភ្នាក់ងារគយនិងរដ្ឋាករបន្ថែមចំនួន២០០ ( ពីររយ ) រូបសំរាប់ឆ្នាំ២០០៥
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សំរេច

**ប្រការ ១** : បង្កើត និងតែងតាំងគណៈកម្មការមួយមានឈ្មោះថា " គណៈកម្មការជ្រើសរើសភ្នាក់ងារគយនិងរដ្ឋាករ " ដែលមានសមាសភាពដូចខាងក្រោម ៖

១- ឯកឧត្តម **ប៉ែន ស៊ីម៉ន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា នាយកទីចាត់ការគយនិងរដ្ឋាករ **ប្រធាន**

២- ឯកឧត្តម **ជូ ទិចិត្ត** អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **អនុប្រធាន**

៣- ឯកឧត្តម **ហ៊ាន សាហ៊ីប** អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **អនុប្រធាន**

៤- លោក **ម៉ម និច** អគ្គាធិការនៃអគ្គាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **អនុប្រធាន**

៥- លោក **មោក សុធារិន** ប្រធាននាយកដ្ឋានបុគ្គលិក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **អនុប្រធាន**

៦- លោក **សៀង ឈុនត្រី** នាយករងទី១ ទីចាត់ការគយនិងរដ្ឋាករ **សមាជិក**

៧- លោក **គុណ ញឹម** នាយករង ទីចាត់ការគយនិងរដ្ឋាករ **សមាជិកអចិន្ត្រៃយ៍**

៨- លោក **ស ខេង** នាយករង ទីចាត់ការគយនិងរដ្ឋាករ **សមាជិក**

៩- លោក **ឡាយ ឫទ្ធី** នាយករង ទីចាត់ការគយនិងរដ្ឋាករ **សមាជិក**

១០- លោក **ឯម យិនទេះ** នាយករង ទីចាត់ការគយនិងរដ្ឋាករ **សមាជិក**

១១- លោក **ប៉ែន សំអាត** ប្រធានការិយាល័យលេខាធិការនិងជំនួយការទីចាត់ការគយនិងរដ្ឋាករ **សមាជិក**

១២- លោក **ឆាំង ទាវិន់ថា** ប្រធានការិយាល័យរដ្ឋបាល-បុគ្គលិកទីចាត់ការគយនិងរដ្ឋាករ **សមាជិក**

១៣- លោក **ខៀវ សំអាន** ប្រធានការិយាល័យគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ **សមាជិក**

១៤- អស់លោក ជំនាញការគយអមទីចាត់ការគយនិងរដ្ឋាករ **ជាអ្នកសង្កេតការណ៍និងផ្តល់យោបល់**

១៥- លោក **ប៊ូ ម៉ុនណារ៉ា** ជំនួយការការិយាល័យបច្ចេកទេសគយ **លេខាធិការ**

**ប្រការ ២** : គណៈកម្មការនេះមានភារកិច្ចដូចតទៅ :

- ចាត់ចែង កសាងគោលការណ៍ចាំបាច់នានាពាក់ពន្ធ័នឹងការងារជ្រើសរើស ភ្នាក់ងារគយនិងរដ្ឋាករ មានជាអាទិ ការកំណត់លក្ខណៈសម្បត្តិ និងជ្រើសរើសបេក្ខជន ការរៀបចំមណ្ឌលប្រឡង ការកំណត់កម្មវត្ថុនៃការប្រឡង ការវាយតំលៃបេក្ខជនមុន និងក្រោយការប្រឡង ការត្រៀមហ្វឹកហ្វឺន ការត្រៀមផ្ទេរ ឬបញ្ចូលក្របខ័ណ្ឌដើម្បីឆ្លើយតបតាមសំណូមពរនៃការជ្រើសរើស ។
- ទំនាក់ទំនងជាមួយ ក្រសួង ស្ថាប័ន និងអង្គការជំនាញពាក់ពន្ធ័ ដើម្បីសុំកិច្ចសហការ និងការចូលរួមក្នុងដំណើរការការងារជ្រើសរើសមន្ត្រីរាជការគយនិងរដ្ឋាករនេះ ក្នុងករណីយល់ថាចាំបាច់។

- ធ្វើរបាយការណ៍ជាប្រចាំនូវការវិវត្តន៍ និងលទ្ធផលដែលទទួលបានតាមដំណាក់និមួយៗ នៃការងារនេះជូនទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។
- បង្កើតអនុគណៈកម្មការមួយចំនួនតាមការចាំបាច់ ដើម្បីទទួលបន្ទុកចាត់ចែង អនុវត្តនូវភារកិច្ច ដោយឡែកៗពីគ្នា ក្នុងគោលបំណងធានាប្រសិទ្ធភាព តំលាភាព និងភាពគ្រប់ជ្រុងជ្រោយនៃការងារនេះ ។

**ប្រការ ៣** : ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា នាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការនាយកដ្ឋាន និងអង្គភាពពាក់ពន្ធ័នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីជនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**គាត ឈន់**

**ចម្លងជូន** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- នាយកខុទ្ទកាល័យ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- នាយកដ្ឋានបុគ្គលិក ( ដើម្បីជូនជ្រាប )
- ដូចប្រការ៣ ( ដើម្បអនុវត្ត )
- ឯកសារ-កាលប្បវត្តិ